# គោលការណ៍ណែនាំភាពជាអ្នកជិតខាងល្អ











PCHR
PHILADELPHIA COMMISSION ON
HUMAN RELATIONS

ទីក្រុង
ហ្វីឡាដែលហ្វៀ



# តារាងមាតិកា


**ស្វាគមន៍** 3

**របៀបធ្វើជាអ្នកជិតខាងល្អ** 4

• ភាពជាអ្នករស់នៅជិតខាងគ្នា
- សម្រាម ការបោះសម្រាម និងចាក់សម្រាមចោល 5
- ការដើរត្រែតត្រត និងការជួបជុំគ្នា 6
- ការលុកលុយ 7
- ការធ្វើឲ្យខូច និងបំផ្លាញទ្រព្យសម្បត្តិសាធារណៈ 8
- ការរុកគួនរំខាន 9
- ការបំភ័យជនភាគតិច 10

**របៀបធ្វើខ្លួនជាអ្នកជិតខាងល្អ** 11

• គោរពព្រំប្រទល់គ្នាទៅវិញទៅមក
- សម្លេងរំខាន 12
- ជប់លៀង និងអាកប្បកិរិយាគ្មានសណ្តាប់ធ្នាប់ 13
- ចំនួនអ្នករស់នៅអតិបរមាក្នុងផ្ទះជួល 14
- ការចូកទឹកកកចេញ 15
- សំណង់បង្កគ្រោះថ្នាក់ 16
- ទីកន្លែងនៅទំនេរ 17
- ការចតយានយន្តមិនត្រឹមត្រូវ និងការបាំងផ្លូវរថយន្ត 18
- រថយន្តដែលបោះបង់ចោល 19
- ការជួសជុលរថយន្តតាមថ្នល់ 20

**រួមគ្នាធ្វើសកម្មភាព** 21

**ទីភ្នាក់ងារក្រុង ជាដៃគូ** 24

**ត្រូវងាកទៅរកនរណាសម្រាប់លទ្ធផល - 311** 26

**រៀបចំផែនការរបស់អ្នក** 28

**តើយើងខ្ញុំជានរណា** 29



# ស្វាគមន៍

យើងខ្ញុំមានក្តីរំភើបដែលហ្វីឡាដែលហ្វៀ ក្នុងនាមជាក្រុងភាតរភាព គឺជាផ្ទះរបស់អ្នក ។ មិនថាអ្នកបានរស់នៅទីនេះពេញមួយជីវិត ឬអ្នកទើបចូលមករស់នៅថ្មីក៏ដោយ សៀវភៅគោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដើម្បីជួយអ្នកអំពីគោលបំណងសំខាន់មួយទៀត គឺ ការធានាបានថា ហ្វីឡាដែលហ្វៀ គឺជាក្រុងដែលពលរដ្ឋមានការស្រឡាញ់រាប់អានគ្នា ។

ផ្នែកមួយនៃបេសកម្មរបស់គណៈកម្មាធិការទំនាក់ទំនងពលរដ្ឋ ហ្វីឡាដែលហ្វៀ (PCHR, Philadelphia Commission on Human Relations) គឺដើម្បីជួយពលរដ្ឋក្នុងការស្វែងរកចំណុចរួម ដើម្បីឲ្យទាំងអស់គ្នាអាចរស់នៅក្បែរគ្នា ដោយមិនមានទំនាស់ ។ យើងខ្ញុំក៏ជួយពលរដ្ឋឲ្យចេះធ្វើការរួមគ្នា ដើម្បីកែលំអស្ថានភាពប្លុក និងតំបន់ក្បែរខាងសម្រាប់រស់នៅ ។ សមាជិកនៃអង្គភាពទំនាក់ទំនងសហគមន៍ (CRD, Community Relations Division) ជួយក្នុងការធ្វើឲ្យកិច្ចការនេះដំណើរការ ទៅបានជារៀងរាល់ថ្ងៃ ។

ក្រុមរបស់យើងខ្ញុំ ចុះធ្វើការដោយផ្ទាល់ជាមួយពលរដ្ឋតាមតំបន់ក្បែរខាង នៅទូទាំងក្រុង ។ ពួកគេ នាំគ្នារៀបចំសិក្ខាសាលាសហគមន៍ ដើម្បីជួយកសាងសមត្ថភាពលើជំនាញដោះស្រាយទំនាស់ ។ ពួកគេក៏បានជួយរកដំណោះស្រាយសមរម្យ ដូចជាការសម្រុះសម្រួល តាមរយៈកម្មវិធីដំណោះស្រាយទំនាស់ (Dispute Resolution Program) ដើម្បីធ្វើជាស្ពាន និងជួយសម្របសម្រួលការទំនាក់ទំនងគ្នារបស់សហគមន៍ ។ ក្នុងករណីមានភាពមិនចុះសម្រុងគ្នានៅក្នុងសហគន៍របស់អ្នក តែជាទំនាស់ដែលមិនបង្កអំពើហិង្សា និងមិនមានការឡើងតុលាការ គឺយើងខ្ញុំអាចជួយសហគមន៍រកវិធីសម្រុះសម្រួលគ្នាបាន ។

យើងខ្ញុំបានបង្កើតឯកសារគោលការណែនាំរបៀបធ្វើជាអ្នករស់នៅក្បែខាងល្អ (Good Neighbor Guide) ក្នុងគោលបំណងផ្តល់នូវធនធានសម្រាប់អ្នក ដើម្បីឲ្យអ្នកអាចចូលរួមជួយធ្វើឲ្យសហគមន៍អ្នក ជាកន្លែងអស្ចារ្យសម្រាប់រស់នៅ ។

ដោយក្តីគោរពរាប់អាន



Kia Ghee
នាយកប្រតិបត្តិ
គណៈកម្មាធិការហ្វីឡាដែលហ្វៀផ្នែកទំនាក់ទំនងពលរដ្ឋ



# របៀបធ្វើជាអ្នកជិតខាងល្អ

## យល់បញ្ហា ស្វែង រកដំណោះស្រាយ

បើមានអ្វីបង្កការរំខានចំពោះអ្នក វាអាចបង្កការរំខានចំពោះអ្នកជិតខាងរបស់អ្នកដែរ ។ អ្នកក្បែរខាងដែលចេះគិតអំពីគ្នាទៅវិញទៅមក អាចរស់នៅក្បែរគ្នាបានល្អ ។ គន្លឹះក្នុងការបង្កើតទំនាក់ទំនងល្អ គឺត្រូវដឹងថាមនុស្សយើងមានភាពខុសគ្នា ហើយមានប្រវត្តិវប្បធម៌ខុសៗគ្នា ហើយចេះគោរពអ្នកជិតខាង អ្នករស់នៅក្នុងប្លុកជាមួយគ្នា និងអ្នករស់នៅក្នុងក្រុងជាមួយគ្នា ។ អ្នកអាចជួបប្រទះរួចមកហើយ ចំពោះមនុស្សមួយចំនួនដែលមានអាកប្បកិរិយាបង្កបញ្ហាជាមួយអ្នកដទៃ តែអ្នកអាចមិនដឹងថាតើត្រូវដោះស្រាយបញ្ហាប្រភេទនេះដោយរបៀបណាឡើយ ។ រៀនពីរបៀបបង្ការបញ្ហាកុំឲ្យរីកធំដែលមិនអាចគ្រប់គ្រងបាន ហើយរកដំណោះស្រាយចំពោះបញ្ហាដែលតែងកើតឡើងដដែលៗ ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## សម្រាម ការបោះសម្រាម និងចាក់សម្រាមចោល

## និយមន័យខ្លីៗ

**បោះសម្រាមចោលតាមថ្នល់ ផ្លូវថ្មើរជើង ឬតាមទីធ្លា ដោយមិនបោះចោលក្នុងធុងសម្រាម គឺជាបោះសម្រាមចោលផ្ដេសផ្ដាស ។ ការបោះចោលរបស់ធំ សម្រាម ឬកំទេចកំទី នៅតាមទីសាធារណៈ ឬទីកន្លែងឯកជន គឺជាការចាក់សំណល់ផ្ដេសផ្ដាស ។ ទង្វើទាំងពីរនេះធ្វើឲ្យអ្នកមើលទៅដូចជាមនុស្សក្បែរខាងដែលមិនល្អ ។ ការចាក់សម្រាមចោលផ្ដេសផ្ដាស ជាអំពើខុសច្បាប់ ។**

### ឧទាហរណ៍

ការបោះកញ្ចប់ដំឡូងបំពង ឬកំប៉ុងសូដាចោលតាមទីធ្លា ដោយមិនបោះវាចោលក្នុងធុងសម្រាម គឺជាការចោលសម្រាមផ្ដេសផ្ដាស ។ ការយកគ្រឿងសង្ហារិមទៅចាក់ចោលលើដីឡូត៍ទំនេរក្នុងប្លុករបស់អ្នក ជាទង្វើដែលហាមឃាត់ ។ ការយកសម្រាមដាក់ត្រង់ចិញ្ចើមថ្នល់មុខផ្ទះរបស់អ្នកក៏មិនអនុញ្ញាតដែរ បើធ្វើខុសថ្ងៃឡានសម្រាមមកប្រមូល ។ មនុស្សនៅក្រៅបរិវេណរបស់អ្នក យកសម្រាមមកចាក់ចោលក្នុងប្លុករបស់អ្នក ក៏ជាទង្វើខុសច្បាប់ដែរ ។

### ហេតុអ្វីបានវាជាបញ្ហា

ការចាក់សម្រាមផ្ដេសផ្ដាសវាធ្វើឲ្យខូចសោភ័ណភាព វានាំឲ្យសត្វល្អិតមករោម វារលួយស្អុយ ហើយបង្កជំងឺ ។ ទីណាមានសម្រាមពាសពេញ ធ្វើឲ្យទីនោះមើលទៅ “ទ្រុឌទ្រោម” ហើយកខ្វក់ ។ វាហាក់ដូចជាពលរដ្ឋនៅទីនោះមិនយកចិត្តទុកដាក់ ហើយវាជាការចូលរួមទង្វើឧក្រិដ្ឋកម្មនៅតំបន់ក្បែរខាង ។ ពេលអ្នកចាក់សម្រាមចោលក្នុងដីឡូត៍ទំនេរ វាអាចពិបាករកមនុស្សប្រមូលចេញ ។

### ដំណោះស្រាយ

យើងមានវិធីត្រឹមត្រូវ ដើម្បីកុំឲ្យមនុស្សចោលសម្រាមផ្ដេសផ្ដាស កាន់សម្រាមតាមខ្លួនរហូតអ្នកដើរដល់កន្លែងមានធុងសម្រាម សឹមបោះវាចោលក្នុងធុងសម្រាមនោះ ។ ប្រាប់ឲ្យអ្នកដទៃធ្វើតាមអ្នក ។ ដាក់ធុងសម្រាមនៅបរិវេណងាយស្រួលក្នុងផ្ទះអ្នក ដើម្បីឲ្យអ្នកងាយចោលសម្រាមក្នុងធុង ។ យករបស់ធំៗដែលត្រូវបោះចោល ទៅកាន់មជ្ឈមណ្ឌលសម្រួលអនាម័យ(Sanitation Convenience Centers) ដែលអ្នកមិនបាច់បង់ថ្លៃចោលរបស់នោះ ។

សូមចូលទៅកាន់ phila.gov/services រួចចុចលើពាក្យ “សម្រាម, ការប្រើឡើងវិញ និងសំអាតក្រុង-Trash, recycling & city upkeep” ដើម្បីស្វែងរកមជ្ឈមណ្ឌលអនាម័យនៅក្បែរអ្នក ។

អ្នកអាចហៅទូរស័ព្ទទៅលេខ 311 ដើម្បីរាយការណ៍ពីការចោល/ចាក់សម្រាមខុសច្បាប់ ។ បើអ្នកអាចថតរូបស្លាកលេខឡានរបស់អ្នកចោលសម្រាមខុសច្បាប់ សាលាក្រុងអាចជួយទប់ស្កាត់មិនឲ្យបុគ្គលនោះយកសម្រាមមកចាក់ចោលក្នុងតំបន់រស់នៅរបស់អ្នកនាពេលខាងមុខ ។ រៀបផែនការទិវាសំអាតតំបន់រស់នៅ ។ កម្មវិធីលើកកម្ពស់ជីវិតសហគមន៍ក្រុង (CLIP, City’s Community Life Improvement Program) អាចឲ្យអ្នកខ្ចីសម្ភារៈផ្គត់ផ្គង់ និងជួយដឹកសម្រាមក្នុងទិវាសំអាតតំបន់រស់នៅរបស់អ្នកទៅចោលបាន ។ សូមហៅទូរស័ព្ទទៅលេខ 311 ដើម្បីស្វែងយល់ព័ត៌មានបន្ថែម ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-700 “ការបដិសេធ និងការចោលសម្រាមផ្ដេសផ្ដាស” ផ្នែកទី 10-703 និង “ការចាក់កំទេចកំទីផ្ដេសផ្ដាស និងការចោលសម្រាមខុសច្បាប់” ផ្នែកទី 10-710 ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## ការដើរត្រេតត្រត និងការជួបជុំគ្នា

## និយមន័យខ្លីៗ

**ការនៅរេរាខាងក្រៅដោយមិនមានមូលហេតុ ឬគោលបំណង ឬការបង្ការមិនឲ្យមនុស្សអាចចេញចូលផ្ទះ ឬបរិវេណអាជីវកម្មបានស្រួល គឺជាការត្រេតត្រតរំខាន ។**

### ឧទាហរណ៍

ការឈររេរាក្នុងរយៈពេលយូរនៅខាងមុខហាង ធ្វើឲ្យអតិថិជនពិបាកចូល ។
អង្គុយលើខឿនមុខផ្ទះអ្នកដទៃដោយមិនមានការអនុញ្ញាត ។
ឈររេរានៅបរិវេណស្ថានីរថភ្លើងក្រោមដី ជាក្រុម ឬម្នាក់ឯង ដោយមិនមានចេតនាជិះរថភ្លើង ។

### ហេតុអ្វីបានវាជាបញ្ហា

ការឈរអែនអនបង្កការរាំងស្ទះហើយ បង្កភាពលំបាកដល់អ្នកដទៃ។ វាអាចធ្វើឲ្យពិបាក បំភ័យអ្នកដទៃ ហើយគ្រោះថ្នាក់បើត្រូវឆ្លងកាត់មនុស្សច្រើន ។

### ដំណោះស្រាយ

ឈរលេងលើជណ្តើរផ្ទះ ឬរានហាលផ្ទះរបស់អ្នក ។
កុំជួបជុំគ្នានៅកន្លែងដែលមិនសម្រាប់ជួបជុំ ។
ជួបមិត្តភក្តិតាមសួនច្បារ ឬនៅតាមបរិវេណខាងក្រៅណាមួយ ។ មិនត្រូវបិទផ្លូវថ្មើរជើង ផ្លូវទ្វារចូល ឬផ្លូវចូលបរិវេណអាជីវកម្ម ហើយចៀសវាងជួបជុំគ្នាជាក្រុមធំ នៅស្ថានីយដឹកជញ្ជូន ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10- 600 “បរិវេណសាធារណៈ - ការប្រព្រឹត្តិដែលត្រូវហាមឃាត់“ ផ្នែកទី 10-603 ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## ការលុកលុយ

## និយមន័យខ្លីៗ

**ការចូលក្នុងបរិវេណ ឬអគារឯកជនដោយមិនបានទទួលការអនុញ្ញាត ឬបន្តនៅក្នុងអគារ ក្រោយម្ចាស់គេប្រាប់ឲ្យអ្នកចេញ គឺជាអំពើលុកលុយ ។**

### ឧទាហរណ៍

ការផ្លោះរបង ដែលមានស្លាកហាមឃាត់មិនឲ្យមនុស្សចូល ។ ការចូលក្នុង ឬការព្យាយាមចូលសារជាថ្មីទៅក្នុងបរិវេណរបស់អ្នកដទៃដោយមិនមានការអញ្ជើញ ។ ការចូលមកវិញក្នុងសួនច្បារ ឬបរិវេណលំហែកាយ ក្រោយបិរវេណនោះបិទទ្វារ គឺជាអំពើលុកលុយ ។

### ហេតុអ្វីបានវាជាបញ្ហា

អំពើលុកលុយគឺគ្រោះថ្នាក់ ហើយខុសច្បាប់ ។ សកម្មភាពរបស់អ្នកអាចធ្វើឲ្យគេភ័យខ្លាច ។ បើអ្នកចូលក្នុងបរិវេណរបស់គេដោយមិនបានទទួលការអញ្ជើញ វាធ្វើឲ្យម្ចាស់ធ្វើអ្វីម្យ៉ាងដើម្បីការពារខ្លួន ។ ពេលខ្លះម្ចាស់គេដាក់ស្លាកថាហាមចូលដោយគ្មានការអនុញ្ញាត ដោយសារទីនោះមានគ្រោះថ្នាក់ ។ បើសិនជានរណាម្នាក់ចូលក្នុងបរិវេណដែលមានស្លាកសញ្ញាហាមឃាត់មិនឲ្យចូលដោយគ្មានការអនុញ្ញាត អ្នកនោះអាចរងរបួសធ្ងន់ធ្ងរ ។

### ដំណោះស្រាយ

ត្រូវយកចិត្តទុកដាក់ចំពោះស្លាកហាមឃាត់ “ហាមចូលដោយគ្មានការអនុញ្ញាត” ។ ហាមចូលក្នុងបរិវេណ ឬកន្លែងឯកជន ដោយគ្មានការអនុញ្ញាត ។ ត្រូវចាកចេញ បើម្ចាស់គេប្រាប់ឲ្យចេញ ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិអំពីការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-800 “សុវត្ថិភាព” ផ្នែកទី 10-840 ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## និយមន័យខ្លីៗ

**ការធ្វើឲ្យខូចខាតចំពោះទ្រព្យសម្បត្តិសាធារណៈ ឬឯកជន អគារទំនេរ ឬផ្ទះមានមនុស្សរស់នៅ ។ ការបំផ្លាញទ្រព្យសម្បត្តិមានរួមបញ្ចូលទ្រព្យសម្បត្តិសាធារណៈ ដូចជាបង្គោលសសរ អំពូលភ្លើង រូបចម្លាក់ និងស្លាកសញ្ញា ។**

### ឧទាហរណ៍

ការគាស់បង្អួចផ្ទះក្បែរខាងដែលមិនមានមនុស្សរស់នៅ ឬការគប់បំបែកអំពូលភ្លើងបំភ្លឺផ្លូវ ។ ការគូររូប សរសេរផ្ដេសផ្ដាសតាមរបង ឬតាមអគារ ។

### ហេតុអ្វីបានវាជាបញ្ហា

ការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិជាអំពើខុសច្បាប់ ហើយធ្វើឲ្យបរិវេណនោះមិនសូវមានភាពទាក់ទាញ ។ ការបង្កការខូចខាតមានគូររូប សរសេរផ្ដេសផ្ដាសច្រើន ជាការលំបាកក្នុងការកសាងបរិវេណរស់នៅឲ្យមានភាពខ្លាំង ហើយអចលនទ្រព្យនៅទីនោះក៏ពិបាកលក់ ឬពិបាកជួល ហើយវាធ្វើឲ្យមានជំងឺផ្សិតរុក្ខជាតិកាន់តែច្រើន ។ ការលុបគំនូរ អក្សរផ្ដេសផ្ដាសចេញ និងជួលជុលអចលនទ្រព្យដែលខូចខាតទាំងនោះឡើងវិញ អាចត្រូវចំណាយច្រើន ។

បើអ្នកត្រូវគេចាប់បានថាជាអ្នកបំផ្លាញទ្រព្យសម្បត្តិ អ្នកអាចរងការចោទប្រកាន់ចំពោះអំពើឧក្រិដ្ឋ ឬត្រូវរងការពិន័យធ្ងន់ធ្ងរ ។

### ដំណោះស្រាយ

សូមរាយការណ៍ហេតុការណ៍បែបនេះទៅកាន់លេខ 311 ។ ត្រូវយកបញ្ហាទៅពិភាក្សាជាមួយអ្នកជិតខាង និងប្រធានប្លុក អំពីអក្សរ រូបគំនូរផ្ដេសផ្ដាស និងការខូចខាតក្នុងសហគមន៍របស់អ្នក ។ អ្នកអាចរាយការណ៍ឲ្យគេលុបអក្សររូបផ្ដេសផ្ដាសចេញពីជញ្ជាំង ដោយហៅទូរស័ព្ទទៅលេខ 311 ។ បើអាចធ្វើបាន សូមចាប់អំពូលភ្លើង ឬកាមេរ៉ាសុវត្ថិភាពនៅក្រៅផ្ទះ ដើម្បីបន្លាចជនខិលខូច ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-500 “ទ្រព្យសម្បត្តិ - ការបង្កការខូចខាត ការធ្វើឲ្យខូចរូបរាង និងការបង្កការរំខាន” ផ្នែកទី 10-501 ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## ការរុកគួនរំខាន

## និយមន័យខ្លីៗ

ការរុកគួនរំខាន អាចជាទង្វើដោយរាងកាយ ឬទង្វើដោយសំដី ។ ការប៉ះពាល់រាងកាយអ្នកដទៃដែលគេមិនប្រាថ្នា ព្យាយាមនិយាយជាមួយគេ នៅពេលដែលគេមិនចង់និយាយជាមួយអ្នក ដេរ ឬស្រែកដាក់គេម្តងហើយម្តងទៀត ឬគម្រាមកំហែងអ្នកដទៃ គឺសុទ្ធតែជាទង្វើការរុកគួនរំខាន ។ សព្វថ្ងៃនៅក្នុងពិភពឌីជិថល ការបង្កការគំរាមកំហែង ឬការបញ្ចេញមតិមិនគប្បីតាមកុំព្យូទ័រ ឬសារតាមទូរស័ព្ទ គឺជា "ការរុកគួនរំខានតាមអិនធឺណិត" ។ សកម្មភាពនេះរួមបញ្ចូលទាំងការសម្លុតធ្វើបាបតាមអ៊ីនធឺណិតរបស់ក្មេងៗផងដែរ ។

### ឧទាហរណ៍

ការហៅទូរស័ព្ទទៅនគរបាលជាបន្តបន្ទាប់អំពីបញ្ហារបស់អ្នកជិតខាងដែលមិនមែនជារឿងឧក្រិដ្ឋកម្ម
ដោយមិនបានសួរនាំពួកគេឲ្យបានដឹងរឿងជាមុន ។ ជេរអ្នកជិតខាងដែលពួកគេមិនបាននិយាយអ្វីដាក់អ្នក ។
កូនរបស់អ្នកផ្ញើសារដែលមានន័យអវិជ្ជមានទៅកូនអ្នកជិតខាង ឬកូនអ្នកនិយាយប្រាប់អ្នកដទៃតាមអនឡាញតៗគ្នាអំពីរឿងរ៉ាវមិនល្អដែលបានឮតាមគ្នារបស់អ្នកណាម្នាក់នៅសាលា ។

### ហេតុអ្វីបានវាជាបញ្ហា

នេះជាទម្រង់នៃអំពើហិងក្សា ។ ការរុកគួនរំខាន
វាធ្វើឲ្យនរណាម្នាក់ដែលជួបប្រទះរឿងបែបនេះ
ឬបានឃើញសកម្មភាពនេះកើតឡើងចំពោះនរណាម្នាក់ មានអារម្មណ៍មិនស្រួលក្នុងខ្លួន ហើយវាមិនជួយក្នុងការបង្កឲ្យមានទំនាក់ទំនងល្អរវាងគ្នាឡើយ ។
វាមិនជម្រុញឲ្យមានភាពរឹងមាំជាមួយអ្នកជិតខាងឡើយ ។
វាធ្វើឲ្យអ្នកដទៃឈឺចាប់ ហើយក្នុងករណីខ្លះទៀតវាជាអំពើខុសច្បាប់ ។

### ដំណោះស្រាយ

ពិនិត្យមើលថាហេតុអ្វីបានជាអ្នកខឹង ។ សួរខ្លួនឯងថា "តើមានអ្វីខ្ញុំអាចផ្លាស់ប្តូរបានទេ?" ឬសួរថា "តើខ្ញុំបានព្យាយាមយកបញ្ហានេះទៅពិភាក្សាជាមួយអ្នកជិតខាងហើយឬនៅ នៅពេលដែលយើងមិនខឹងគ្នានោះ?" ជាញយៗ អ្នកជិតខាងអ្នកអាចមិនបានដឹងថាអាកប្បកិរិយារបស់ពួកគេបង្កឲ្យមានរឿងបែបនេះ ។
យើងខ្ញុំសូមផ្តល់អនុសាសន៍ឲ្យអ្នកយកបញ្ហាបែបនេះទៅពិភាក្សាជាមួយអ្នកជិតខាង ក្រោយរឿងត្រូវបានបញ្ចប់ នៅពេលអ្នកបាត់ខឹង ឬការប្រឈមដាក់គ្នាត្រូវបានបញ្ចប់ ។
បើអ្វីដែលអ្នកចង់ធ្វើមិនអាចដំណើរការរលូនបានទេ សូមទាក់ទង PCHR ឲ្យជួយសម្របសម្រួលការពិភាក្សានេះ ។ អ្នកអាចទាក់ទងជាមួយនឹងកម្មវិធីដោះស្រាយទំនាស់របស់ PCHR តាមលេខ 215-686-4670 ។

### ច្បាប់

អ្នកអាចអានច្បាប់ដែលស្ថិតក្រោមក្រមផេនស៊ីលវេណៀ ចំណងជើងទី 18 (Pennsylvania code Title 18) ផ្នែកទី 2709 ។

# ភាពជាអ្នករស់នៅជិតខាងគ្នា

## ការបំភ័យជនភាគតិច

## និយមន័យខ្លីៗ

**ការគូរ ឬសរសេររូបសញ្ញាបង្ហាញភាពស្អប់ខ្ពើមនៅតាមផ្ទះ ឬនៅតាមបរិវេណសាធារណៈ ឬឯកជន បណ្តាលឲ្យមហាជនភ័យខ្លាចកើតហិង្សា— ជាពិសេសចំពោះអ្វីពាក់ព័ន្ធនឹងជាតិសាសន៍ ជាតិពន្ធុ ឬបញ្ហាសាសនា ។**

### ឧទាហរណ៍

ការគូររូបសញ្ញាពាក់ព័ន្ធនឹងរបបណាស៊ី
ឬរូបសញ្ញាផ្សេងទៀតបង្កភាពប៉ះពាល់ចំពោះពូជសាសន៍
នៅតាមអគារ ឬនៅតាមជញ្ជាំងនៅក្នុងតំបន់រស់នៅ ។
សរសេរសារចំពោះការប្រកាន់ពូជសាសន៍
ឬប្រឆាំងនឹងអន្តោប្រវេសន៍ នៅតាមផ្ទះនរណាម្នាក់ ។
ការធ្វើឲ្យខូចរូបចម្លាក់សាសនា នៅតាមទីកន្លែងគោរពបូជា ។

### ហេតុអ្វីបានវាជាបញ្ហា

ក្រុងហ្វីឡាដែលហ្វៀប្រកាន់យកភាពចម្រុះ
ហើយទាត់ចោលភាពស្អប់ខ្ពើម ។ ការប្រើពាក្យ
និងសញ្ញានៃភាពស្អប់ខ្ពើម ជាអំពើបង្កើតភាពឈឺចាប់
និងខុសច្បាប់ ។ ការបំភិតបំភ័យ
ជានិច្ចកាលវាធ្វើឲ្យប៉ះពាល់ចំពោះមនុស្សច្រើនគ្នា
ក្រៅតែពីមនុស្សដែលអ្នកផ្តោតលើ អ្នករស់នៅក្បែរខាងទាំងអស់
អាចរងការភិតភ័យ ។ មិនថាស្ថិតក្នុងករណីណាឡើយ អ្នកមិនអាច
យកការបំភិតបំភ័យជនភាគតិចមកលេងសើចបានទេ
វាមិនមែនជារឿងគួរឲ្យអស់សំណើចឡើយ ។ កម្មវត្ថុ សកម្មភាព
និងអាកប្បកិរិយាបែបនេះ វាធ្វើឲ្យមានការឈឺចាប់
ហើយមានប្រវត្តិបង្កភាពអាក់អន់ចិត្ត ។

### ដំណោះស្រាយ

ត្រូវស្វែងរកវិធីដែលមានន័យ ក្នុងការស្វែងយល់ក្រុមមនុស្សមាន
វប្បធម៌ខុសៗគ្នា ដែលរស់នៅក្បែរខាងអ្នក តាមរយៈការសន្ទនា
ជាមួយមនុស្សដែលមានប្រវត្តិខុសៗគ្នា ។
ចូលរួមសកម្មភាពវប្បធម៌សហគមន៍
ហើយទាក់ទងស្គាល់គ្នាជាមួយនរណាម្នាក់ដែលមានពូជសាសន៍
សាសនា ឬសញ្ជាតិខុសពីអ្នក ។
បើកចិត្តទូលាយទទួលយកភាពខុសគ្នា ហើយស្វែងរកចំណុចរួម ។
ស្វែងរកសៀវភៅពីបណ្ណាល័យប្រចាំមូលដ្ឋានរបស់អ្នក
ដែលសរសេរអំពីសាសនា ក្រុមជនភាគតិច និងវប្បធម៌ផ្សេងៗ ។
អ្នកអាចចូលរួមជួយធ្វើឲ្យសហគមន៍របស់យើងជាសហគមន៍បើកចំហ
ហើយជាកន្លែងស្វាគមន៍មនុស្សគ្រប់រូប ។

បើអ្នកឃើញសកម្មភាពបង្កការបំភិតបំភ័យចំពោះជនភាគតិចនៅក្បែរខាងអ្នក សូមកុំលាក់ទុក ហើយត្រូវរាយការណ៍បញ្ហានេះ ដោយការហៅទូរស័ព្ទទៅកាន់ PCHR តាមលេខ 215-686-4670 ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តនិងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-200 “ការបំភិតបំភ័យជនភាគតិច និងការបង្កភាពខូចខាតសាសនា និងជំនឿ” ផ្នែកទី 10-202 ។



# របៀបធ្វើខ្លួនជាអ្នកជិតខាងល្អ

## យល់បញ្ហា ស្វែងរកដំណោះស្រាយ

ការរស់នៅទីក្រុង
មានន័យថារស់នៅតាមកន្លែងរៀងៗខ្លួនដែលបិទទ្វារជិត ។
នៅតំបន់ទីក្រុង ដូចជាក្រុងហ្វីឡាឌែលហ្វៀ
ដែលជាអ្នកបង្កើតឲ្យមានផ្ទះសាងសង់ជាជួរៗ
គឺជាហេតុនាំឲ្យមានការរស់នៅ ដោយត្រូវបិទទ្វារជិតរៀងៗខ្លួន ។
ត្រូវដឹង និងធ្វើតាមបទបញ្ញត្តិរបស់ក្រុង ដែលបានបង្កើតឡើង
ដើម្បីជួយពលរដ្ឋឲ្យចេះរស់នៅជាមួយគ្នា ជាអ្នកជិតខាងល្អចំពោះគ្នា ។
ចេះបែងចែកទីកន្លែងរស់នៅដែលមានបរិវេណតូចជាមួយអ្នកដែលរស់នៅជាប់ និងជុំវិញអ្នក ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## សម្លេងរំខាន

## និយមន័យខ្លីៗ

**មានបទបញ្ញត្តិអំពីប្រភេទសម្លេងឡូឡា និងកម្រិតសម្លេង ដែលអាចទទួលយកបាននៅក្នុងផ្ទះជិតខាង និងនៅតាមបរិវេណសាធារណៈ ដោយលែងលែងតែសម្លេងសកម្មភាពសាងសង់ និងសម្លេងយន្តហោះ ។**

### ឧទាហរណ៍

ការអង្គុយស្តាប់ចម្រៀងក្នុងឡាន ដោយបើកសម្លេងខ្លាំង ហើយខ្ទ័រដល់អ្នកខាងក្រៅ ។ មើលទូរទស្សន៍ក្នុងផ្ទះរបស់ខ្លួន ដោយបើកសម្លេងខ្លាំងឮឆ្លងជញ្ជាំង និងឮដល់អ្នកនៅក្រៅផ្ទះ ។

### ហេតុអ្វីបានវាជាបញ្ហា

ការធ្វើឲ្យមានសម្លេងខ្លាំង វាបង្កការរំខាន ហើយវាជាការឈ្លានពានតំបន់រស់នៅរបស់អ្នកដទៃ ដោយរួមទាំងការបើកសម្លេងខ្លាំង វាអាចធ្វើឲ្យមនុស្សខូចក្រដាសត្រចៀកទៀតផង ។ សម្លេងដែលគេមិនចង់ឮ ឬសម្លេងដែលខ្លាំងហួសប្រក្រតី អាចបង្កការរំខានដល់អ្នកជិតខាងមិនឲ្យស្តាប់អ្វីដែលពួកគេកំពុងស្តាប់ ឬធ្វើឲ្យពួកគេគេងមិនបាននៅពេលយប់ ។ សម្លេងខ្លាំងក៏អាចបង្កការរំខានមិនឲ្យនរណាម្នាក់អាចស្តាប់ឮអ្វីដែលសំខាន់ចំពោះសុវត្ថិភាពរបស់ពួកគេ ដូចជាសម្លេងព្រមាន ឬសម្លេងយានយន្តមានទិសដៅមករកពួកគេ ។

### ដំណោះស្រាយ

ត្រូវគិតអំពីអ្នកនៅជុំវិញ និងអ្នកជិតខាង ជាពិសេសក្រោយពីម៉ោង 9 យប់ នៃថ្ងៃធ្វើការ ឬក្រោយម៉ោង 11 យប់ នាថ្ងៃចុងសប្តាហ៍ ។ សូមកុំបង្កការរំខានចំពោះការសម្រាករបស់អ្នកដទៃ ត្រូវចងចាំថាទារកគេងនៅពេលថ្ងៃ កុមារទៅសាលា ហើយអ្នកដទៃត្រូវការសម្រាកយកកម្លាំងធ្វើការ ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-400 “សម្លេងរំខាន និងសម្លេងខ្ទ័រខ្លាំង” ផ្នែកទី 10-403 ។

# គោរពព្រាំប្រទល់គ្នាទៅវិញទៅមក

## និយមន័យខ្លីៗ

**ការរំខានសន្តិភាពអ្នកដទៃ សកម្មភាពដែលបង្កការរំខាន ឬបង្កកង្វល់ចំពោះសាធារណៈ ឬអាកប្បកិរិយាដែលបង្កហានិភ័យចំពោះអ្នកដទៃ គឺជាទង្វើមិនមានសណ្តាប់ធ្នាប់ ដែលត្រូវទទួលទោស បើទោះបីអ្នកជាអនីតិជនក៏ដោយ ។**

### ឧទាហរណ៍

ការជប់លៀងដោយមានសម្លេងឡូឡាខ្លាំង ដែលរំខានអ្នកជិតខាង ឬ “រំខានដល់” ទីកន្លែងសាធារណៈ ។ បោះសម្រាម បូករួមទាំងកំប៉ុង និងដបចោលតាមថ្នល់ ។ នោមដាក់ទ្រព្យសម្បត្តិអ្នកដទៃ ។ បើកចម្រៀងខ្លាំងជ្រុល ឬបើកខ្លាំងនៅពេលយប់ជ្រៅ ។ ការវាយតប់គ្នា ការប្រើភាសាអាសគ្រាម ឬអាកប្បកិរិយាបង្កគ្រោះថ្នាក់ ។

### ដំណោះស្រាយ

ព្យាយាមស្គាល់អ្នកជិតខាង និងមានមោទនភាពចំពោះអ្នកជិតខាង ។ ចូលរួមការសំអាតប្លុករស់នៅ ។ ចូលរួមការប្រជុំសមាគមន៍របស់អ្នកជិតខាង ។ ចូរចងចាំថាតាមច្បាប់ អំពើល្មើស អាចទទួលផលវិបាកខ្លាំង បើទោះបីជាកូនតូចរបស់អ្នកជាអ្នកបង្កក៏ដោយ ។

### ហេតុអ្វីបានវាជាបញ្ហា

អ្នករស់នៅក្នុងតំបន់ទាំងអស់ចង់ រីករាយចំពោះការរស់នៅរបស់ខ្លួនប្រកបដោយសុវត្ថិភាព ហើយបានទទួលការគោរពពីអ្នកជិតខាង ។ វាជារឿងដែលខ្វះការពិចារណា ហើយវាអាចក្លាយជាគ្រោះថ្នាក់ នៅពេលមនុស្សបង្កភាពពរំខាន ឬបង្កការខូចខាតនៅតាមកន្លែងក្បែរខាង ឬបរិវេណប្រកបអាជីវកម្ម ។

### ច្បាប់

អ្នកអាចអានច្បាប់នេះក្នុងក្រុមហ៊ុឡាខែលហ្វៀ - ចំណងជើង “បទបញ្ញត្តិនៃការប្រព្រឹត្ត និងសកម្មភាពរបស់បុគ្គលម្នាក់ៗ” ជំពូកទី 10-1600 “អាកប្បកិរិយានៅតាមទីប្រជុំជនសាធារណៈ: ការវិនិច្ឆ័យចំពោះផ្នែករដ្ឋបាលលើការរំលោភបំពាន ”ផ្នែកទី 10-1603 ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## ចំនួនអ្នករស់នៅអតិបរមាក្នុងផ្ទះជួល

## និយមន័យខ្លីៗ

**រូបមន្តចំពោះចំនួនមនុស្សអនុញ្ញាតឲ្យរស់នៅក្នុងបរិវេណមួយ គឺសាលាក្រុងជាអ្នកកំណត់ ហើយត្រូវគណនាដោយគិតអំពីក្រឡាផ្ទៃរួមនៃទីតាំងនោះ ជាហ្វីតការ៉េ ។ លើសពីនេះ គេមិនអនុញ្ញាតឲ្យមនុស្សដែលមិនជាប់សាច់ឈាមគ្នា មិនមានទំនាក់ទំនងគ្នាតាមអាពាហ៍ពិពាហ៍ ឬតាមបែបកូនឪពុកម្ដាយចិញ្ចឹម អាចរស់នៅរួមគ្នាក្នុងបន្ទប់ស្នាក់នៅមួយលើសពីបីនាក់ឡើយ ។**

### ឧទាហរណ៍

ផ្ទះជួរដែលមានទំហំតូច អាចសម្រាប់តែមនុស្សប្រាំមួយនាក់រស់នៅ ហើយវានឹងបង្កឲ្យមានបញ្ហា បើសិនជាអ្នករស់នៅមានចំនួនប្រាំបី ឬ 10 នាក់ បើទោះបីជាក្នុងនោះមានខ្លះជាកុមារ ហើយមកពីគ្រួសារតែមួយក៏ដោយ ។ អ្នកជួលផ្ទះឲ្យគេស្នាក់នៅគឺលើសចំនួនកំណត់ ប្រសិនបើផ្ទះដែលអ្នកជួលឲ្យគេគឺសម្រាប់នៅតែបួននាក់ តែឥឡូវមានអ្នករស់នៅដល់ទៅប្រាំបីនាក់ ។

### ហេតុអ្វីបានវាជាបញ្ហា

ផ្ទះនីមួយៗ មានទំហំកំណត់សម្រាប់បរិវេណរស់នៅ និងបន្ទប់គេង ការរស់នៅលើសចំនួនកំណត់ វាមិនល្អចំពោះសុខភាព ។ ការរស់នៅច្រើនគ្នា មានន័យថាអ្នកត្រូវប្រើលក្ខណៈជាមូលដ្ឋានរបស់ផ្ទះ ដូចជាបន្ទប់បាយ និងបន្ទប់ទឹកហួសកំណត់ ។ ក្រៅពីការធ្វើខុសលក្ខ័ណ្ឌការជួលហើយ គឺអ្នកអាចកំពុងតែបណ្ដោយខ្លួនឲ្យស្ថិតក្នុងគ្រោះថ្នាក់ចំពោះសុខភាព និងសុវត្ថិភាពផងដែរ ។ អ្នកក៏អាចបង្កការរំខានចំពោះបរិដ្ឋានដែលកំពុងតែមានសុខសន្តិភាព នៃបរិវេណរបស់អ្នកជួលផ្សេងទៀតផងដែរ ។ ការពិត បើសិនមានមនុស្សច្រើនហួសហេតុរស់នៅក្នុងផ្ទះអ្នក សាលាក្រុងអាចចេញលិខិតជូនដំណឹងបញ្ហាឲ្យអ្នកចាកចេញពីផ្ទះនេះ ។

### ដំណោះស្រាយ

វាអាចពិបាកក្នុងការប្រាប់មិត្តភក្តិ ឬសាច់ញាតិថាគេមិនអនុញ្ញាតឲ្យមនុស្សថែមទៀតស្នាក់នៅក្នុងផ្ទះនេះ តែបើអ្នកមិនធ្វើបែបនេះទេ អ្នកអាចត្រូវបណ្ដេញចេញពីផ្ទះនេះ ។ មុនពេលអនុញ្ញាតឲ្យមនុស្សបន្ថែមទៀតចូលស្នាក់នៅក្នុងផ្ទះរបស់អ្នក ត្រូវព្យាយាមនាំពួកគេស្វែងរកផ្ទះផ្សេងដើម្បីរស់នៅសិន ។

អាជ្ញាធរគេហកិច្ចហ្វីឡាដែលហ្វៀ (Philadelphia Housing Authority) មានព័ត៌មានអំពីទីភ្នាក់ងារផ្ដល់ជំនួយការជួលផ្ទះដើម្បីរស់នៅ ។
www.pha.phila.gov/housing. aspx

ការិយាល័យក្រុងផ្នែកគេហកិច្ច និងការអភិវឌ្ឍសហគមន៍ (Division of Housing and Community Development)
មានព័ត៌មានសម្រាប់ជំនួយគ្រាអាសន្នផ្នែកគេហកិច្ច ៖
www.phila.gov/departments/division-of-housing-and-community-development/

### ច្បាប់

អ្នកអាចអានច្បាប់នេះក្នុងផ្នែកទី PM-202 និង PM-404 នៃក្រមការថែទាំអចលនទ្រព្យហ្វីឡាដែលហ្វៀ និងផ្នែកទី 14-102(49) នៃក្រមបែងចែកតំបន់ហ្វីឡាដែលហ្វៀ ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## ការចូកទឹកកកចេញ

## និយមន័យខ្លីៗ

**សំអាតទឹកកក ឬព្រិលនៅតាមផ្លូវថ្មើរជើងដែលមានកម្រាស់យ៉ាងហោចណាស់បីហ៊្វីត នៅមុខផ្ទះ ឬបរិវេណអាជីវកម្មរបស់អ្នក ដើម្បីឲ្យអ្នកថ្មើរជើងអាចដើរកាត់តាមនេះដោយស្រួល ។ត្រូវចាប់ផ្តើមសំអាតក្នុងរវាងប្រាំមួយម៉ោង ក្រោយព្រិលឈប់ធ្លាក់ ។ កុំភ្លេចគិតអំពីផ្លូវជម្រាលចេញទៅថ្នល់ ដោយសំអាតព្រិក ឬទឹកកកចេញឲ្យអស់ ដើម្បីសម្រួលដល់អ្នកជិតខាងដែលប្រើរទេះរុញអាចចេញចូលបានស្រួល ។**

## ឧទាហរណ៍

ការមិនបានចូកទឹកកកចេញពីផ្លូវថ្មើរជើងនៅមុខផ្ទះ ឬឲ្យអ្នកដទៃចូកឲ្យ ។ ការមិនចូកទឹកកកចេញ យូរថ្ងៃក្រោយឈប់ព្យុះ ។ ការចូកទឹកកកចេញមិនត្រឹមត្រូវ ដែលបិទផ្លូវឡាន ច្រកចេញចូល អ្នកជិតខាងរបស់អ្នក ។ ការយករបស់រាងសាជីមូល ឬកៅអីមកដាក់តាមថ្នល់ដើម្បីរក្សាបរិវេណសម្រាប់ចតឡាន គឺជាអំពើខុសច្បាប់ ។

## ហេតុអ្វីបានវាជាបញ្ហា

ទឹកកក និងព្រិលអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ។ អ្នកមិនចង់ឃើញនរណាម្នាក់ដើរក្បែរផ្ទះរបស់អ្នកហើយ រអិលដួល និងរងរបួសធ្ងន់ធ្ងរឡើយ - រួមទាំងរូបអ្នកផងដែរ ។ ព្រិល និងទឹកកកអាចបិទច្រកចេញចូលថ្នល់ ដែលវាបង្កផលលំបាកចំពោះជនពិការក្នុងការចេញចូល ប្រកបដោយសុវត្ថិភាព ។

## ដំណោះស្រាយ

រៀបផែនការ និងត្រៀមខ្លួនជាមុន ។ ទិញប៉ែល និងឧបករណ៍រំលាយទឹកកកទុកជាមុន សម្រាប់ប្រើក្នុងរដូវធ្លាក់ទឹកកក ។ បើអ្នកមិនអាចចូកទឹកកកចេញទេ អ្នកអាចសុំឲ្យគ្រួសារ មិត្តភក្តិ ឬអ្នកជិតខាងជួយ ដើម្បីឲ្យបរិវេណផ្លូវថ្មើរជើងក្បែរផ្ទះរបស់អ្នកស្អាតក្រោយព្រិលឈប់ធ្លាក់ ។

## ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code - Title 10) ។ "បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ ជំពូកទី 10-700 "ការបដិសេធ និងការចោលសម្រាមផ្តេសផ្តាស" ផ្នែកទី 10-720 "ការសំអាតព្រិលពីផ្លូវថ្មើរជើង" ។

# គោរពព្រាំប្រទល់គ្នាទៅវិញទៅមក

## សំណង់បង្កគ្រោះថ្នាក់

## ការពណ៌នាខ្លីៗ

**អគារ ឬសំណង់ដែលមិនមានការថែទាំត្រឹមត្រូវ ដោយមានស្នាមប្រេះតាមជញ្ជាំង មានរបស់ធ្លាក់មកដី ឬមានទំនងចង់រលំ គឺសុទ្ធតែអ្វីដែលអាចបង្កគ្រោះថ្នាក់ ។**

### ឧទាហរណ៍

ផ្ទះដែលខូចខាត របាំងឈើពុក ផ្ទះដែលមានរានហាលមិនរឹងមាំ ឬមានដំបូលច្រេងច្រោង ។

### ហេតុអ្វីបានវាជាបញ្ហា

ការបាក់រលំភ្លាមៗរបស់អគារ អាចធ្វើឲ្យឡានចតក្បែរខាងខូចខាត ស្ទះផ្លូវ ធ្វើឲ្យអគារនៅក្បែរមិនរឹងមាំ - ឬអាចសម្លាប់ជីវិតនរណាម្នាក់ក៏ថាបាន ។ មិនត្រូវចូលក្នុងអគារដែលទុកចោលទំនេរឡើយ គេអាចចោទប្រកាន់ថាអ្នកបំពានតំបន់ហាមឃាត់ ហើយនៅក្នុងនោះវាអាចមានគ្រោះថ្នាក់ដែលអ្នកមើលមិនឃើញ ។

### ដំណោះស្រាយ

សូមរាយការណ៍អំពីអគារ ឬសំណង់ដែលមើលទៅមិនមានសុវត្ថិភាព ឬត្រូវកំទេចចោល ដោយចុចទូរស័ព្ទទៅលេខ 311 ។ សំអាតវាចេញឲ្យអស់ ។ បើអ្នកជាម្ចាស់កម្មសិទ្ធិរបស់នោះ ត្រូវរៀបចំជួសជុល ឬរើចេញឲ្យអស់ជាបន្ទាន់! បើអ្នកគិតថាអគារនោះវាអាចរលំភ្លាមៗ សូមហៅទូរស័ព្ទទៅលេខ 911 ដើម្បីសុំជំនួយ ។

### ច្បាប់

អ្នកអាចអានច្បាប់ទាំងអស់នេះនៅត្រង់ផ្នែកទី PM-305, 310 & 311 នៃក្រមការថែទាំអចលនទ្រព្យហ្វីឡាដែលហ្វៀ ។

# គោរពព្រាំប្រទល់គ្នាទៅវិញទៅមក

## ទីកន្លែងនៅទំនេរ

## និយមន័យខ្លីៗ

**អគារ ឬដីឡូត៍ដែលទុកចោលទំនេរ នៅតែត្រូវការការយកចិត្តទុកដាក់ និងការថែទាំតាំងពី សន្តិសុខ រហូតដល់ភាពស្អាតបាត ។ ម្ចាស់អចលនទ្រព្យត្រូវមានអាជ្ញាប័ណ្ណទុកអចលនទ្រព្យឲ្យនៅទំនេរ បើសិនជាអគារនោះត្រូវ ទុកឲ្យនៅទំនេរ ។**

## ឧទាហរណ៍

អចលនទ្រព្យមួយក្លាយជារបស់ទំនេរ ពេលមិនមាននរណាម្នាក់រស់នៅទីនោះ ។ វាអាចជាផ្ទះទទេរ ឬដីឡូត៍ទំនេរ មិនមានសាងសង់ផ្ទះ ។ អចលនទ្រព្យមួយអាចនៅទំនេរ ដោយសារម្ចាស់ឈឺ ស្លាប់ ឬម្ចាស់ដាក់អគារនោះសម្រាប់លក់ ឬទីនោះមិនមានអ្នកជួលនៅ ហើយម្ចាស់មិនថែទាំវា ។

## ហេតុអ្វីបានវាជាបញ្ហា

មនុស្សអាចគាស់ចូលអគារទំនេរ ដែលមិនបានចាក់សោឲ្យបានត្រឹមត្រូវ និងមិនមានមនុស្សនៅ ។ អគារទុកចោល អាចក្លាយជាកន្លែងចាក់សម្រាម ហើយជាបរិវេណកណ្តុរ និងសត្វល្អិតរស់នៅ ។ ការមិនរក្សាសម្រស់ផ្ទះ/អគាររបស់អ្នក វាបង្កផលប៉ះពាល់ចំពោះតម្លៃអចលនទ្រព្យនៅក្បែរខាងរបស់អ្នក ។ អ្វីៗទាំងអស់នេះ វាមិនបានជួយឲ្យមនុស្សមានសុខភាពល្អ ឬ ធ្វើឲ្យសហគមន៍គួរជាទីរស់នៅឡើយ ។

## ដំណោះស្រាយ

ម្ចាស់អចលនទ្រព្យ ជានិច្ចកាល ត្រូវទទួលខុសត្រូវលើការថែទាំ បើទោះបីជាវានៅទំនេរមិនមានអ្នករស់នៅក៏ដោយ ។ រៀបចំអចលនទ្រព្យឲ្យមានសុវត្ថិភាព ។ ចេញចូល ដើម្បីពិនិត្យមើល ។ បើផ្ទះ ឬអគារត្រូវការជួសជុល អ្នកត្រូវរៀបផែនការជួសជូល ឬរៀបផែនការដើម្បីលក់ចេញ ។ អ្នកក៏ត្រូវមានអាជ្ញាប័ណ្ណទុកអចលនទ្រព្យឲ្យនៅទំនេរ ដើម្បីឲ្យសាលាក្រុងដឹងថាត្រូវទាក់ទងអ្នកដោយរបៀបណា បើសិនជាមានបញ្ហា ។ អ្នកជិតខាងអាចរាយការណ៍ពីគេហដ្ឋានដែលមិនបំពេញតាមលក្ខខ័ណ្ឌតម្រូវទាំងនេះ ដោយការចុចទូរស័ព្ទទៅលេខ 311 ។

## ច្បាប់

អ្នកអាចអានច្បាប់នេះត្រង់ផ្នែកទី PM-306 នៃក្រមការថែទាំអចលនទ្រព្យហ្វីឡាដែលហ្វៀ ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## ការចតយានយន្តមិនត្រឹមត្រូវ និងការបាំងផ្លូវរថយន្ត

## និយមន័យខ្លីៗ

**នៅពេលយើងនាំគ្នាចតឡានតាមទីកន្លែងមិនអនុញ្ញាត ឬមិនគោរពស្លាកសញ្ញាការចតយានយន្តដែលបញ្ជាក់ពេលកំណត់ឲ្យចត មានន័យថាពួកគេកំពុងចតយានយន្តដោយខុសច្បាប់ ។ មិនត្រូវបាំងផ្លូវឡាន ឬចតឡានទុកចោលរាំងស្ទះចរាចរណ៍ ។**

### ឧទាហរណ៍

ការចតយានយន្តដែលបាំងផ្លូវបើកបរ អ្នកដទៃ ឬចតលើផ្លូវចេញចូលរបស់អ្នកដទៃដោយមិនបានទទួលការអនុញ្ញាត ។ ការចតយានយន្តនៅតាមផ្លូវថ្មើរជើង ចតកៀកនឹងផ្លូវកែង ចតពីរជួរ ឬចតឡានរាំងស្ទះចរាចរណ៍ បង្កគ្រោះថ្នាក់ចំពោះអ្នកដទៃ ។ ការចតឡានត្រង់បរិវេណរក្សាទុកសម្រាប់ជនពិការ ឬទុកសម្រាប់យានយន្តមានស្លាកលេខសម្គាល់ជនពិការ អាចរងការផាកពិន័យធ្ងន់ធ្ងរ ។

### ហេតុអ្វីបានវាជាបញ្ហា

ការបាំងផ្លូវចេញចូលអាចធ្វើឲ្យអ្នកជិតខាងខឹងសម្បារ ហើយវាធ្វើឲ្យគេ ចេញទៅធ្វើការ ឬទៅពេទ្យមិនបាន ។ ការប្រើប្រាស់បរិវេណធំពេក អាចរារាំងមិនឲ្យអ្នកដទៃចតកើត ។ ការចតមិនត្រឹមត្រូវមិនឲ្យឡានចេញទៅផ្លូវធំបាន ឬអាចបត់តាមផ្លូវកែងបានស្រួល អាចរារាំងនគរបាល យានយន្តសង្គ្រោះបន្ទាន់ ឡានក្រុង ឬឡានប្រមូលសម្រាមធ្វើកិច្ចការរបស់ពួកគេបានស្រួល ។ ការចតឡាននៅតាមផ្លូវថ្មើរជើងអាចបង្កគ្រោះថ្នាក់សម្រាប់អ្នកដើរ ឬចំពោះការរត់លេងរបស់កុមារ ។ ការចតនៅបរិវេណសម្រាប់ជនពិការ ធ្វើឲ្យជនពិការពិបាករកកន្លែងមានសុវត្ថិភាព និងងាយចតសម្រាប់ពួកគេ ។

### ដំណោះស្រាយ

បើអ្នកជាអ្នកដំណើរ សូមពិនិត្យស្លាកសញ្ញាចតយានយន្តនៅតាមផ្លូវឲ្យបានច្បាស់ ។ មកឲ្យបានលឿនដើម្បីរកកន្លែងចតយានយន្ត ហើយសូមចតតែត្រង់បរិវេណស្របច្បាប់ ។ វាប្រសើរជាងក្នុងការចតឡានពីរបីប្លុកពីកន្លែងដែលយើងចង់ចត ដើម្បីចៀសវាងការផាកពិន័យអស់រាប់រយដុល្លាក្នុងការផាកម្ដងៗ ។ ពេលអ្នកស្ថិតក្នុងបរិវេណរស់នៅរបស់ខ្លួន ត្រូវគិតសិនមុននឹងចតថា តើការចតនេះវារាំងស្ទះដល់ផ្លូវចេញចូលរបស់អ្នកក្បែរខាងដែរឬទេ ។ ត្រូវនិយាយគ្នាអំពីបញ្ហាការចតយានយន្ត មុនពេលដែលបញ្ហាកើតឡើង ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 10 (Philadelphia Code – Title 10) ។ “បទបញ្ញត្តិនៃការប្រព្រឹត្តិ និងសកម្មភាពរបស់បុគ្គលម្នាក់ៗ ជំពូកទី 10-800 “សុវត្ថិភាព” ផ្នែកទី 10-823 “ផ្លូវឡានចេញចូល” និងចំណងជើងទី 12 ។ “ក្រមចរាចរណ៍ ជំពូកទី 12-900 “បទបញ្ញត្តិការចតយានយន្ត និងការផាកពិន័យ” ផ្នែកទី 12-913 និងផ្នែកទី 12-2405 ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## រថយន្តដែលបោះបង់ចោល

## និយមន័យខ្លីៗ

**ឡានតូច ឬឡានធំដែលបញ្ឆេះមិនឆេះ គ្មានអ្នកមើលថែ បែកកង់ ឬបាត់កង់ ឬមិនមានស្លាកលេខត្រឹមត្រូវ អាចចាត់ទុកថាជាឡានដែលគេបោះចោល ។**

### ឧទាហរណ៍

ឡានអ្នកបើកលែងកើត ឬបែកកង់ ហើយអ្នកមិនអាចយកវាទៅជួសជុលបាន ដូច្នេះអ្នកទុកវាចោលតាមផ្លូវ ។ ឡានដែលមានផ្លាកចុះបញ្ជី និងបានទទួលការត្រួតពិនិត្យដែលផុតកំណត់លើសពី 90 ថ្ងៃ ។ ឡានដែលចតចោលខុសច្បាប់លើសពី 48 ម៉ោង ។

### ហេតុអ្វីបានវាជាបញ្ហា

ឡានបាក់បែក ខូចខាត ទុកចោលតាមផ្លូវ អាចបង្កខូចសោភ័ណភាព ហើយជួនកាលអាចទទួលរងការបំផ្លាញ ។ ស្ថានភាពបែបនេះវាអាចធ្វើឲ្យខាតកន្លែងចតយានយន្តដែលមានតម្លៃក្នុងតំបន់ដែលអ្នករស់នៅ ។ នៅពេលគេចាប់ផ្តើមសម្គាល់ថា ឡាននេះត្រូវបានចតចោលជាយូរ ហើយគេរាយការណ៍ដល់អាជ្ញាធរ ពេលនោះឡានរបស់អ្នកត្រូវស្ថិតក្នុងហានិភ័យពីការប្រកាសថាជាឡានដែលគេបោះចោល ហើយគេនឹងសណ្តោងយកទៅជាមិនខាន ។

### ដំណោះស្រាយ

បើឡានអ្នកមានបញ្ហា សូមប្រាប់អ្នកជិតខាងឲ្យបានដឹង ហើយពន្យល់ឲ្យពួកគេយល់ពីស្ថានភាពរបស់អ្នក ។ ត្រូវព្យាយាមគ្រប់វិធី ដើម្បីឲ្យជាងជួសជុលឡានរបស់អ្នក ឬសណ្តោងចេញពីផ្លូវក្នុងរវាង 48 ម៉ោង ។ បើអ្នកសង្ស័យថាឡានណាមួយត្រូវម្ចាស់ទុកចោលក្នុងប្លុកផ្ទះរបស់អ្នក ត្រូវរាយការណ៍បញ្ហានេះ ដោយចុចទៅលេខ 311 មុនពេលបញ្ហាអាចកើតឡើង ។ នគរបានអាចដាក់ស្ទើរបាយការណ៍អំពីឡាននេះ ហើយចាប់ផ្តើមធ្វើការស៊ើបអង្កេត ។ ឡានតូច ឬឡានធំ អាចត្រូវគេសណ្តោងចេញ ។

ព័ត៌មានអំពីឡានត្រូវម្ចាស់ទុកចោល អាចរកអានបាននៅឯ http://www.phillypolice.com/assets/directives/D12.6-AbandonedVehicles.pdf

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 12 (Philadelphia Code - Title 10) ។ “ក្រមចរាចរណ៍” ជំពូកទី 12-1100 “បទបញ្ញត្តិផ្សេងៗ និងការផាកពិន័យ” ផ្នែកទី 12-1120 “ឡានដែលម្ចាស់ទុកចោល” ។

# គោរពព្រំប្រទល់គ្នាទៅវិញទៅមក

## ការជួសជុលរថយន្តតាមថ្នល់

## និយមន័យខ្លីៗ

**ការបង្កើតអាជីវកម្ម ដូចជាលាងសំអាតឡានពេញលេញ ឬលាងឡាននៅតាមផ្លូវ ត្រូវបានហាមឃាត់ ។ ត្រង់នេះគឺរួមបញ្ចូលនូវការជួលជុលឡាននៅតាមថ្នល់ លើកលែងតែករណីគ្រោះអាសន្ន ។**

### ឧទាហរណ៍

ការដូរជុំហ្វ្រាំងឡានអ្នក ក្នុងពេលកំពុងចតនៅតាមផ្លូវ ។
ធ្វើអាជីវកម្មលាងសំអាតឡាន នៅមុខផ្ទះរបស់អ្នក ។

### ហេតុអ្វីបានវាជាបញ្ហា

ដំណើរការអាជីវកម្មនៅតាមថ្នល់ គឺជាសកម្មភាពបង្កការរំខាន ហើយវាអាចមានគ្រោះថ្នាក់ចំពោះអ្នកជិតខាង ។ ការប្រតិបត្តិការអាជីវកម្មនៅតាមថ្នល់ អាចមិនមានលទ្ធភាពយករបស់មានគ្រោះថ្នាក់ចេញផុតពីថ្នល់ដោយសុវត្ថិភាព ។ កាកសំណល់យានយន្ត ដូចជាប្រេងម៉ាស៊ីន គឺមិនអាចចាក់ចូលក្នុងលូបង្ហូរទឹកភ្លៀងបានឡើយ ។

### ដំណោះស្រាយ

ការជួសជុលឡានក្នុងតម្លៃថោកគឺគួរឲ្យទាក់ទាញ តែមិនមែនជួលជុលឡាននៅលើថ្នល់មុខផ្ទះឡើយ ។ បើអ្នកត្រូវការជួសជុលឡានតូច ឡានធំ ឬម៉ូតូ ត្រូវស្វែងរកហាង ឬភ្នាក់ងារតំណាង សម្រាប់ជួសជុល ។ អ្នកមិនអាចប្រើផ្លូវថ្នល់សាធារណៈ សម្រាប់ដំណើរការអាជីវម្មដូចជាការលាងឡាន ឬលាងសំអាតឡានពេញលេញបានឡើយ ។

### ច្បាប់

អ្នកអាចរកច្បាប់នេះមកអានពីក្រមក្រុងហ្វីឡាដែលហ្វៀ-ចំណងជើងទី 12 (Philadelphia Code - Title 10) ។ “ក្រមចរាចរណ៍” ជំពូកទី 12-900 “បទបញ្ញត្តិការចតយានយន្ត និងការផាកពិន័យ” ផ្នែកទី 12-902 ។

# រួមគ្នាធ្វើសកម្មភាព

ការទទួលបានចំណេះដឹងអំពីបញ្ហាដែលអាចកើតឡើងចំពោះអ្នកក្បែរខាង និងដឹងអំពីដំណោះស្រាយដែលអាចទៅរួច គឺដូចជាទទួលបានជោគជ័យកណ្ដាលនៃសមរភូមិ ។ រៀបចំដើម្បីទទួលបានជោគជ័យពាក់កណ្ដាលទៀត ។ សិក្សាអំពីដៃគូនៅចំពោះមុខ និងអង្គការដែលអាចជួយអ្នកបាន និងរកវិធីចាប់ក្រុមជាមួយគ្នា ដើម្បីបង្កើតសហគមន៍ដែលអ្នកត្រូវការ ។ ការកសាង និងរក្សាឲ្យបាននូវតំបន់ក្បែរខាងដែលល្អ ដើម្បីងាយស្រួលរស់នៅ គឺមិនអាចធ្វើឡើងដោយការខិតខំតែម្នាក់ឯងបានទេ ។ វាត្រូវធ្វើការងាជាក្រុម ។ ការរៀបចំតំបន់រស់នៅក្បែរខាងឲ្យបានល្អ តម្រូវឲ្យមានបណ្ដាញមនុស្សដែលមានបំណងចង់ធ្វើការរួមគ្នា ហើយមានការជួយជ្រោមជ្រែងស្មើៗគ្នាចំពោះភាពជោគជ័យ ។ សូមឆែកមើលកម្រងព័ត៌មានខាងក្រោម ដែលរៀបរាប់អំពីតួអង្គសំខាន់ៗ ដែលអាចជួយអ្នកឲ្យសម្រេចគោលបំណងនេះបាន!



## ប្រធានប្លុក

ប្រហែលជារូបអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ អាចធ្វើជាប្រធានប្លុកបានល្អ ។ តើអ្នកមានប្រធានប្លុកហើយឬនៅ? ត្រូវរកវិធីដើម្បីស្គាល់បុគ្គលនេះ ហើយប្រាប់គាត់ថាអ្នកចង់ជួយ។ នេះគឺជាការពណ៌នាអំពីប្រធានប្លុក ។

- ជ្រើសរើសដោយអ្នករស់នៅក្នុងប្លុកទាំងអស់ ។
- ដើរតួនាទីជាទូតសម្រាប់ប្លុក ។
- កោះហៅការប្រជុំប្រចាំខែ ដើម្បីកំណត់អាទិភាពបញ្ហា និងរៀបចំគោលដៅ ។
- ដឹកនាំសកម្មភាព ដូចជាសកម្មភាពសំអាតប្លុក ឬសុំការអនុញ្ញាតរៀបចំការជប់លៀងរបស់អ្នករស់នៅក្នុងប្លុក ។
- ធ្វើការជាមួយមន្ត្រីជាប់ឆ្នោត ។
- ពាំនាំតម្រូវការអ្នករស់នៅក្នុងប្លុកទៅកាន់អាជ្ញាធរ ។
- អាចប្រមូលថវិកាវិភាគទាន សម្រាប់ចេញការចំណាយលើគម្រោងសកម្មភាពរបស់ប្លុក ដូចជាការរៀបចំសួនច្បារសហគមន៍ ការរំលែកទុក្ខ ឬការរៀបចំតុបតែងសម្រាប់ថ្ងៃសម្រាកជុំគ្នានៅខាងក្រៅ ។

ដើម្បីស្វែងយល់បន្ថែមអំពីប្រធានប្លុក សូមចូលទៅកាន់ philadelphiastreets.com ហើយស្វែងរកពាក្យ “ប្រធានប្លុក-block captains” ។

## សមាគមពាណិជ្ជកម្មប្រចាំមូលដ្ឋាន

សមាគមនេះ ជាទូទៅ មានចំណាប់អារម្មណ៍ជាពិសេសចំពោះការកែលំអសម្រស់ផ្លូវធំ ឬមជ្ឈមណ្ឌលពាណិជ្ជកម្ម ហើយជួយជម្រុញឲ្យអាជីវកម្មក្នុងមូលដ្ឋានជោគជ័យ ។ Mt. សមាគមពាណិជ្ជកម្មអែរី (Airy Business Association) និង សមាគមពាណិជ្ជកម្មវិថីបាល់ទីម៉ នៃហ្វីឡាដែលហ្វៀខាងលិច (Baltimore Avenue Business Association of West Philadelphia) គឺជាឧទាហរណ៍ចំនួនពីរប្រចាំក្រុង ដែលនៅមានសមាគមពាណិជ្ជកម្មជាច្រើនផ្សេងទៀត ។ ពួកគេជាក្រុមដែល ៖

- តំណាងឲ្យអាជីវកម្មខ្នាតតូចនៅក្នុងមូលដ្ឋាន ។
- ផ្តោតលើពាណិជ្ជកម្មក្នុងទ្រង់ទ្រាយតូច ជួនកាលអាជីវកម្មនៅតាមច្រករបៀងពីរបីប្លុក ។
- ធ្វើជាដៃគូជាមួយអ្នកជិតខាង ដើម្បីជួយជ្រោមជ្រែង និងលើកកម្ពស់សហគមន៍ដែលខ្លួនបម្រើ ។

សមាគមពាណិជ្ជកម្មប្រចាំមូលដ្ឋានភាគច្រើនរបស់ហ្វីឡាដែលហ្វៀ មានរាយឈ្មោះក្នុងបញ្ជី RCO ហ្វីឡាដែលហ្វៀ តាមអាសយដ្ឋាន https://www. phila.gov/CityPlanning/projectreviews/RCO

## អង្គការសហគមន៍ចុះបញ្ជីត្រឹមត្រូវ
## (RCO, Registered Community Organization)

RCO ដើរតួជាផ្នែកមួយដែលពលរដ្ឋក្រុងហ្វីឡាដែលហ្វៀ អាចប្រើដើម្បីទទួលបានព័ត៌មាន ហើយធ្វើឲ្យអ្នកក្លាយជាអ្នកចូលរួមដែលបានដឹងរឿងទាំងអស់អំពីដំណើរការចាត់ចែងតំបន់ ។ ពួកគេធ្វើការទៅតាមគោលការណ៍ណែនាំ ដែលរៀបចំដោយគណៈកម្មាធិការផែនការក្រុមហ្វីឡាដែលហ្វៀ (PCPC, Philadelphia City Planning Commission) ។

- RCO ត្រូវបានបង្កើតឡើង ជាវិធីមួយ សម្រាប់បញ្ចូលពលរដ្ឋទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ជុំវិញការអភិវឌ្ឍន៍ ការប្រើប្រាស់ដី ។
- ប្រសិនបើមានការស្នើសុំការរៀបចំតំបន់ផ្សេងៗ ឬស្នើសុំការលើកលែងពិសេសសម្រាប់អចលនទ្រព្យ RCO ដែលជាអ្នកតំណាងតំបន់នោះ ត្រូវរៀបចំការប្រជុំសាធារណៈក្នុងរវាង 45 ថ្ងៃ ។ នរណាក៏អាចចូលរួមការប្រជុំទាំងនេះបានដែរ ។
- នៅពេលអ្នកបានឃើញស្ទិកឃ័រពណ៌ទឹកក្រូចខ្ចីបិទជាប់នឹងអចលនទ្រព្យនៅក្នុងតំបន់ក្បែរខាងអ្នក សូមអានឲ្យបានជ្រាបជាព័ត៌មានអំពីការស្នើសុំរៀបចំតំបន់សម្រាប់អចលនទ្រព្យនោះ ។
- បើសិនជាអ្នកមិនយល់កិច្ចការណាមួយអំពីគម្រោងអភិវឌ្ឍន៍ឬអចលនទ្រព្យក្នុងតំបន់ក្បែរខាងអ្នក សូមទាក់ទង RCO ប្រចាំមូលដ្ឋានរបស់អ្នក ។

PCPC ជាអ្នករក្សាទុកបញ្ជី RCOs ទាំងអស់ដែលនៅដំណើរការ ។ អ្នកអាចស្វែងយល់បន្ថែមអំពី RCOs របស់ក្រុង តាមអាសយដ្ឋាន https://www. phila.gov/CityPlanning/projectreviews/Pages/RegisteredCommunityOrganizations.aspx

## សមាគមខុនដូឬសមាគមម្ចាស់ភាគហ៊ុនខុនដូ
### (Condo or Co-Op Owners Association)

នៅក្នុងទីក្រុងនេះ មានសហគមន៍ ខុនដូជាច្រើន ។ បើសិនអ្នកជាផ្នែកមួយនៃសមាគមខុនដូ ឬអ្នកកំពុងចាប់អារម្មណ៍រើទៅរស់នៅក្នុងខុនដូ នេះជាតួនាទីមួយចំនួនរបស់សមាគមខុនដូ ៖

- កំណត់ និងជម្រុញឲ្យមានការអនុវត្តបទបញ្ញត្តិរបស់ខុនដូ ។
- ប្រមូលប្រាក់វិភាគទានប្រចាំខែ ត្រីមាស ឬប្រចាំឆ្នាំ ។
- ថែរក្សា និងជួសជុលបរិវេណទទួលខុសត្រូវរួមគ្នា ដូចជាសួនច្បារ ជណ្តើរយន្ត ឬអាងហែលទឹក ។
- ស្វែងរកវិធីដើម្បីរក្សាឲ្យបាន ឬជម្រុញ តម្លៃរបស់បន្ទប់ (ផុង) នៅក្នុងខុនដូ ។
- អនុវត្តតាមច្បាប់គេហកិច្ចរបស់សហព័ន្ធ រដ្ឋ និងមូលដ្ឋាន ។

## សាជីវកម្មអភិវឌ្ឍន៍សហគមន៍ (CDC, Community Development Corporation)

ខាងក្រោមជាការពណ៌នាអំពី CDC និងការទទួលខុសត្រូវរបស់សាជីវកម្ម ៖

- អង្គការមិនរកកម្រៃដែលធ្វើការជួយសហគមន៍ក្រីក្រ
- ជួយដោះស្រាយបញ្ហា ដូចជាកសាង ឬកសាងឡើងវិញនូវតំបន់ឧស្សាហកម្មក្នុងសហគមន៍ និងផ្តល់ផ្ទះដែលមានតម្លៃសមរម្យ
- ផ្តល់សេវាកម្ម ដូចជាការថែទាំសុខភាព ការបណ្តុះបណ្តាលការងារ ឬការអប់រំ ។
- ទទួលថវិកាឯកជន និងថវិការដ្ឋ ។
- ធ្វើការជាមួយរដ្ឋាភិបាល តែមិនមែនជាផ្នែកមួយនៃរដ្ឋាភិបាលឡើយ ។

**វិបសៃត**: http://pacdc.org

## ក្រុមប្រឹក្សាភិបាលនគរបាលឧស្សាហ៍ (PDAC, Police District Advisory Council)

PDAC ត្រូវបានបង្កើតឡើងសម្រាប់ដើរតួជាអ្នកធ្វើទំនាក់ទំនងសម្របសម្រួលរវាងនាយកដ្ឋាននគរបាល និងសហគមន៍ ។

កម្មវិធី PDAC ៖

- ប្រតិបត្តិការក្នុងឧស្សាហ៍ 21 នៃឧស្សាហ៍នគរបាលចំនួន 23
- សមាជិកក្រុមមានអ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកតំណាងរបស់ការិយាល័យអគ្គមេធាវីឧស្សាហ៍ ។
- រៀបចំការប្រជុំប្រចាំខែ ដើម្បីពិភាក្សាអំពីបញ្ហាបង្កផលប៉ះពាល់ចំពោះគុណភាពជីវិតពលរដ្ឋរស់នៅក្នុងឧស្សាហ៍ ។
- ជ្រើសរើសមន្ត្រីតំណាង PDAC សម្រាប់ចូលរួមប្រជុំជាមួយស្នងការនគរបាល និងសមាជិកផ្នែកបញ្ញាការនគរបាល ។

**វិបសៃត ៖** https://philadelphiada.org/police-district-advisory-commission

## គណៈកម្មការសម្រស់ហ្វីឡាដែលហ្វៀ (PMBC, Philadelphia More Beautiful Committee)

PMBC គឺជាក្រុមរបស់នាយកដ្ឋានផ្លូវថ្នល់ហ្វីឡាដែលហ្វៀ ផ្នែកអនាម័យ (Philadelphia Streets Department, Sanitation Division) ។ បើអ្នកចាប់អារម្មណ៍អំពី តំបន់រស់នៅស្អាត អ្នកអាចបង្កើតក្រុម ដើម្បីនាំគ្នាធ្វើឲ្យកិច្ចការនេះកើតឡើង ។ នេះគឺជាការទទួលខុសត្រូវខ្លះៗ របស់ PMBC ៖

- ជួយរៀបចំ និងជ្រោមជ្រែងប្រធានប្លុក ។
- ដើរតួជាអ្នកទំនាក់ទំនងសម្របសម្រួល រវាងពលរដ្ឋ និងរដ្ឋាភិបាលក្រុង ដើម្បីផ្តល់ធនធានរបស់នាយកដ្ឋាន ព័ត៌មាន និងសេវាកម្ម ពាក់ព័ន្ធនឹងការធ្វើឲ្យប្លុករបស់ខ្លួនជាកន្លែងស្អាតមិនមានសម្រាម និងមានសោភ័ណភាព ។
- ឧបត្ថម្ភចំពោះការសំអាតប្លុករស់នៅ ។
- រៀបចំការប្រកួតប្រជែងប្លុកស្អាតគ្មានសម្រាម គ្រប់រដូវស្លឹកឈើជ្រុះ ដោយមានផ្តល់រង្វាន់ចំពោះជ័យលាភីផងដែរ ។

**វិបសៃត ៖** https://www.philadelphiastreets.com/pmbc

# ទីភ្នាក់ងារក្រុង ជាដៃគូ

សាលាក្រុងបានបង្កើតទីភ្នាក់ងារមួយចំនួន ដើម្បីបម្រើសេចក្តីត្រូវការជាក់ស្តែងរបស់សហគមន៍ក្នុងទីក្រុងនេះ ។

ទាក់ទងការិយាល័យក្រុងណាមួយក្នុងចំណោមការិយាល័យទាំងអស់នេះ ដើម្បីស្នើសុំព័ត៌មាន ឬសុំជំនួយចំពោះបញ្ហាពិសេសនានា ។



## ការិយាល័យអភិបាលក្រុងសម្រាប់ជនមានពិការភាព

ធ្វើការដើម្បីធានាថា សាលាក្រុង ជាទីកន្លែងដែលផ្តល់ការជ្រោមជ្រែងដល់ពលរដ្ឋទាំងអស់ ដោយមិនគិតអំពីស្ថានភាពរាងកាយ ភ្នែក បញ្ញា និងត្រចៀកឡើយ ។

- ការិយាល័យនេះមានតួនាទីភ្ជាប់ជនមានពិការភាព ជាមួយនឹងសេវាកម្មពាក់ព័ន្ធសម្រាប់ជនមានពិការភាព ក្នុងការជ្រោមជ្រែងចំពោះច្បាប់ជនមានពិការភាពអាមេរិកាំង (Americans with Disabilities Act) ច្បាប់យុត្តិធម៌គេហកិច្ច (Fair Housing Act) និងច្បាប់ផ្សេងៗទៀត ។
- នេះជាបញ្ហាមួយចំនួនដែលការិយាល័យនេះអាចជួយបាន ៖
    - សុវត្ថិភាពគេហកិច្ច
    - ឱកាសការងារ
    - ការបោះឆ្នោត
    - ការរៀបចំកុំឲ្យមានរបាំងឧបសគ្គ រៀបចំផ្លូវជម្រាលថ្មើរជើងឲ្យបានល្អ
    - ឱកាសអប់រំ
    - ការលំហែកាយ សិល្បៈ និងវប្បធម៌
    - សេវាកម្មសុខភាពផ្លូវចិត្ត
    - សេវាកម្មសុខភាព និងសេវាកម្មបម្រើពលរដ្ឋ

**សាលាក្រុង បន្ទប់ 260D | ហ្វីឡាដែលហ្វៀ PA 19107**
**ទូរស័ព្ទ ៖** 215.686.2798
**វិបសៃត៍ ៖** https://www.phila.gov/departments/mayors-office-for-people-with-disabilities/

## ការិយាល័យកិច្ចការអន្តោប្រវេសន៍

- មានតួនាទីលើកកម្ពស់សុខុមាលភាពសហគមន៍អន្តោប្រវេសន៍ហ្វីឡាដែលហ្វៀ ។
- ជួយបង្កើតគោលនយោបាយ និងកម្មវិធីដែលនឹងផ្តល់ឱកាស និងការទទួលបានសេវាកម្ម ។
- ធ្វើការដើម្បីសម្របសម្រួលដាក់បញ្ចូលជនអន្តោប្រវេសន៍ទៅក្នុងសកម្មភាពពលរដ្ឋ សេដ្ឋកិច្ច និងជីវិតវប្បធម៌ក្រុង ។
- គូសបញ្ជាក់អំពីតួនាទីរបស់ជនអន្តោប្រវេសន៍ ដែលបានអនុវត្ត និងបន្តអនុវត្ត ក្នុងសង្គមរបស់យើង ។

**1401 John F. មហាវិថីកេណីឌី បន្ទប់ 1430 | ផេនស៊ីលវេណៀ 19102**
**ទូរស័ព្ទ** 215.686.0876
**វិបសៃត៍ ៖** https://www.phila.gov/departments/office-of-immigrant-affairs/

## ការិយាល័យកិច្ចការ LGBT

គស្ស៊ូមតិដើម្បីរាប់បញ្ចូល និងដើម្បីការពារពលរដ្ឋ LGBTQ និងការអភិវឌ្ឍន៍របស់សហគមន៍ LGBTQ

- ធ្វើការដើម្បីតស៊ូមតិចំពោះបញ្ហារបស់ LGBTQ នៅទូទាំងតំបន់របស់រដ្ឋាភិបាលក្រុង
- ធ្វើជាចំណុចសម្រាប់ទំនាក់ទំនងរវាងសហគមន៍ LGBTQ និងសាលាក្រុង
- ជួយបង្កើតគោលនយោបាយអំពីបញ្ហាសិទ្ធិពលរដ្ឋ ដែលប៉ះពាល់ដល់ពលរដ្ឋ LGBTQ

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាលអតីតយុទ្ធជនហ្វីឡាដែលហ្វៀ

មានតួនាទីទំនាក់ទំនងបុគ្គលជាអតីតយុទ្ធជនហ្វីឡាដែលហ្វៀ ដើម្បីឲ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ និងសេវាកម្មដែលពួកគេគួរតែទទួលបាន

- ស្វែងរក និងបញ្ជូនក្រុមអតីតយុទ្ធជនឲ្យទៅទទួលសេវាកម្មពីទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីផ្តល់ជូនពួកគេនូវសេវាកម្មប្រឹក្សាយោបល់ និងសេវាកម្មផ្សេងៗទៀត ។
- ភ្ជាប់អតីតយុទ្ធជនជាមួយនឹងព័ត៌មាន អង្គការ និងធនធានដែលពួកគេត្រូវការ ។
- ជួយសមាជិកក្នុងការទទួលសេវាកម្មអន្តរកាល និងគ្រួសាររបស់ពួកគេ ក្នុងការត្រឡប់ ទៅផ្ទះវិញក្រោយការទទួលសេវាកម្ម ។

**សាលាក្រុង បន្ទប់ 127 | ហ្វីឡាដែលហ្វៀ 19102**
**ទូរស័ព្ទ ៖** 216.686.3256
**វិបសៃត៍ ៖** http://www.phlveterans.com

## ប្រយុទ្ធប្រឆាំងចំពោះការរាតត្បាតការញៀនអាភៀន ៖

សាលាក្រុងខិតខំធ្វើការដើម្បីសង្គ្រោះជីវិតមនុស្ស លើកកម្ពស់ឲ្យពលរដ្ឋអាចទទួលបានជំនួយកាន់តែប្រសើរជាងមុន ព្រមទាំងប្តូរឥទ្ធិពលអវិជ្ជមានបញ្ហាអាភៀនដែលមានលើសហគមន៍យើងដោយពង្រឹងការងារបង្ការ និងការងារអប់រំ ។

- រៀនពីរបៀបស្នើសុំ និងប្រើប្រាស់ថ្នាំណាឡូសូន (Narcan®) ថ្នាំប្រើសម្រាប់បន្សាបការប្រើប្រាស់អាភៀនលើសកំណត់ ។
- នរណាក៏អាចទិញថ្នាំណាឡូសូនពីឱសថស្ថានបានដែរ ដោយគ្រាន់តែមានវេជ្ជបញ្ជា ឬប្រើលិខិតបញ្ជាទិញថ្នាំណាឡូសូនរបស់រដ្ឋផេនស៊ិលវេនៀ (Pennsylvania Naloxone Standing Order) ដែលសរសេរឡើងសម្រាប់ពលរដ្ឋទូទៅប្រើប្រាស់ ដែលមានបង្ហោះនៅឯវិបសៃត៍ www.health.pa.gov ។

បើអ្នកគិតថាមាននរណាម្នាក់ប្រើប្រាស់ថ្នាំហួសកំណត់ សូមហៅទូរស័ព្ទទៅលេខ 911 ។ នាយកដ្ឋាននគរបាល និងអគ្គិភ័យមានថ្នាំណាឡូសូន ដែលជាសារធាតុបន្សាបការប្រើអាភៀនលើសកម្រិត ក្នុងស្តុក ហើយពួកគេអាចផ្តល់ការថែទាំបន្ថែមទៀតផងដែរ ។ ត្រូវស្វែងរកការព្យាបាល ដើម្បីចៀសវាងការប្រើអាភៀនលើសកម្រិត ។ សម្រាប់ព័ត៌មានបន្ថែមសូមចុចទូរស័ព្ទទៅលេខ (800) 662-HELP (4357) ។ បើអ្នកមានសំណួរអំពីថ្នាំណាឡូសូន សូមអ៊ីម៉េលទៅកាន់ overdose.prevention@phila.gov ។

**សាលាក្រុង បន្ទប់ 115 | ហ្វីឡាដែលហ្វៀ PA 19107 ទូរស័ព្ទ ៖** 215.686.0330
**វិបសៃត៍ ៖** https://www.phila.gov/departments/office-of-lgbt-affairs/



# ត្រូវងាកទៅរកនរណាសម្រាប់លទ្ធផល 3-1-1

ការសំអាត និងកែលំអសហគមន៍អ្នក គឺជាកិច្ចការធំ ។ ជួនកាលវាមានន័យថា ជាការស្វែងរកជំនួយពីខាងក្រៅតំបន់ក្បែរខាងអ្នក និងងាកទៅរកជំនួយពីដៃគូសាលាក្រុងឲ្យជួយ ។ សាលាក្រុងមានសេវាកម្ម និងបណ្តាញច្រើនដែលអ្នកអាចពឹងពាក់បាន អ្នកអាចទាក់ទងពួកគេដោយផ្ទាល់ តែពួកគេក៏អាចជួយអ្នកបានដែរ ដោយការហៅទូរស័ព្ទទៅលេខ “311” ។ ចំពោះការហៅទូរស័ព្ទពីខាងក្រៅក្រុងហ្វីឡាដែលហ្វៀ សូមចុចលេខ 215-686-8686 ។ នេះជាចំណុចចាប់ផ្តើមដែលអ្នកអាចស្វែងរកជំនួយ ដោះស្រាយបញ្ហារបស់អ្នក ។ បើជំនួយដែលអ្នកត្រូវការមិនមានរាយនៅទីនេះទេ សូមហៅទូរស័ព្ទទៅលេខ “311” ហើយសួរនាំពួកគេ ។

# សូមចងចាំ

## បើអ្នកបានឃើញ ឬមានកង្វល់អំពីបញ្ហាឧក្រិដ្ឋកម្ម សូមហៅទូរស័ព្ទទៅលេខ “911”

| កង្វល់ | ត្រូវទៅទីណា |
|---|---|
| • ការចាក់សម្រាមខុសច្បាប់<br>• ធុងសម្រាមដែលមានសម្រាមហៀរហូរចេញក្រៅ | **ផ្នែកអនាម័យនៃនាយកដ្ឋានផ្លូវថ្នល់ហ្វីឡាដែលហ្វៀ (Philadelphia Streets Department Sanitation Division)**<br>3-1-1 |
| • គម្លើងឧបករណ៍សញ្ញាព្រមាន ឬបញ្ចេញសម្លេងខ្លាំង<br>• ក្លិនស្អុយ (ហៅទៅលេខ 911 បើអ្នកធុំក្លិនហ្គាស ឬក្លិនផ្សែង) | **ការគ្រប់គ្រងខ្យល់អាកាស នាយកដ្ឋានសុខភាពហ្វីឡាដែលហ្វៀ (Philadelphia Health Department)**<br>215.685.7580 ឬ<br>3-1-1 |
| • អគារដែលគេបោះបង់ ឬអគារគ្រោះថ្នាក់<br>• មានការជួសជុលឡាននៅតាមថ្នល់<br>• បោះសម្រាមចោលនៅតាមដីឡូត៍ | **សេវាកម្ម និងប្រតិបត្តិការអាជ្ញាប័ណ្ណ និងការត្រួតពិនិត្យហ្វីឡាដែលហ្វៀ (Services and Operations Philadelphia Licenses & Inspections)** 3-1-1 |
| • ដើមឈើប៉ះខ្សែភ្លើង<br>• ដើមឈើដួលលើខ្សែភ្លើង | **សេវាកម្មគ្រាអាសន្ន PECO**<br>800.841.4141 |
| • ឡានដែលគេចតទុកចោល<br>• ឡានខូចបើកទៅមុខមិនរួច | **នាយកដ្ឋាន កងនគរបាលហ្វីឡាដែលហ្វៀ ផ្នែកសេវាកម្មសហគមន៍ (Neighborhood Services Unit Philadelphia Police Department)** 215.685.9500 ឬលេខ 3-1-1 |
| • ការអនុញ្ញាតឲ្យជប់លៀងក្នុងប្លុក<br>• សម្រាម/របស់ប្រើប្រាស់ឡើងវិញមិនមានអ្នកមកប្រមូល<br>• គ្រលុកតាមថ្នល់<br>• ថ្នល់គ្របដណ្តប់ដោយព្រិល/ទឹកកក<br>• ផ្លូវថ្មើរជើងដែលគ្រោះថ្នាក់<br>• អំពូលភ្លើងតាមផ្លូវដែលខូច<br>• ស្លាកសញ្ញាផ្លូវថ្នល់បាត់/បែកបាក់ | **កិច្ចការអតិថិជន នាយកដ្ឋានផ្លូវថ្នល់ហ្វីឡាដែលហ្វៀ**<br>215.686.5560 ឬលេខ 3-1-1 |
| • បាបង្កការរំខាន ឬកន្លែងសំចតមួយរយៈពេលខ្លី<br>• ក្មេងមិនគ្រប់អាយុផឹកគ្រឿងស្រវឹង<br>• ហាងផឹកស៊ីខុសច្បាប់ | **កងនគរបាលរដ្ឋផេនស៊ីលវេញៀផ្នែកគ្រប់គ្រងគ្រឿងស្រវឹង (Liquor Control Enforcement Squad Pennsylvania State Police)** 800.932.0602 ឬលេខ 3-1-1 |
| • ឆ្កែព្រុសរំខាន<br>• សត្វគ្មានម្ចាស់<br>• សត្វព្រៃ<br>• ការជុះអាចមន៍ដាក់ទីធ្លាជាប្រចាំ (ច្រើនជាង 12 ម៉ោង)<br>• សត្វចិញ្ចឹមនៅកសិដ្ឋាន (ជ្រូក មាន់ ។ល។) ក្រោយផ្ទះ | **ក្រុមថែទាំ និងគ្រប់គ្រងសត្វ (ACCT ហ្វីលី)**<br>សេវាកម្មគ្រាអាសន្ន 24 ម៉ោង៖ 267.385.3800 |

# រៀបចំផែនការរបស់អ្នក

ឥឡូវដោយសារអ្នកបានដឹងព័ត៌មានមូលដ្ឋានមួយចំនួន អ្នកអាចត្រៀមខ្លួនរួចរាល់ក្នុងការអនុវត្តសកម្មភាព បើមានបញ្ហាកើតឡើង តែអ្នកក៏អាចយកបញ្ហាទាំងនោះដាក់បញ្ចូលក្នុងនេះ ដោយការបង្កើត គោលការណ៍ណែនាំសម្រាប់ខ្លួនអ្នកអនុវត្តបានដែរ ។

សូមបំពេញទំព័រ ធ្វើផែនការផ្ទាល់ខ្លួនរបស់អ្នក ហើយរក្សាវាទុកក្បែរខ្លួន ។ បើអ្នកជាប់គាំងចំពោះចម្លើយមួយចំនួន អ្នកអាចស្នើសុំជំនួយបានដោយ ៖

- ពិភាក្សាជាមួយអ្នកជិតខាង
- ឆែកមើលព័ត៌មានក្នុងវិបសៃត៍របស់សាលាក្រុងហ្វីឡាដែលហ្វៀ តាមអាសយដ្ឋាន ៖ www.phila.gov
- ចូលទស្សនាវិបសៃត៍គណៈកម្មាធិការសេវិនធី (Committee of Seventy) ដើម្បីស្វែងរកព័ត៌មានអំពីមន្ត្រីជាប់ឆ្នោត ៖ www.seventy.org
- ហៅទៅលេខ 311
- ហៅទូរស័ព្ទទៅកាន់សាខាបណ្ណាល័យរបស់អ្នក

**បំពេញបែបបទនេះ ហើយបង្កើតធនធានមគ្គុទ្ទេសក៍របស់អ្នកផ្ទាល់ ហើយរក្សាលេខទំនាក់ទំនងរបស់អ្នកក្នុងផ្ទៃកតេចេញលឿន!**

## ប្រធានប្លុករបស់ខ្ញុំ / អ្នកតំណាង HOA

ឈ្មោះ ៖

អាសយដ្ឋាន ៖

## នគរបាលឧស្រ្តិករបស់ខ្ញុំ ៖

ឈ្មោះមន្ត្រីទំនាក់ទំនងសហគមន៍របស់ខ្ញុំ ៖

## អ្នកតំណាងឧស្រ្តិករបស់ខ្ញុំ ជាមួយក្រុមប្រឹក្សាក្រុង ៖

ឈ្មោះការិយាល័យសេវាកម្មទំនាក់ទំនងសម្របសម្រួលមណ្ឌលបោះឆ្នោត ៖

## អ្នកតំណាងរដ្ឋខ្ញុំ ៖

ឈ្មោះការិយាល័យសេវាកម្មទំនាក់ទំនងសម្របសម្រួលមណ្ឌលបោះឆ្នោត:

## ព្រឹទ្ធសភារដ្ឋខ្ញុំ ៖

ឈ្មោះការិយាល័យសេវាកម្មទំនាក់ទំនងសម្របសម្រួលមណ្ឌលបោះឆ្នោត ៖

## ព័ត៌មានទំនាក់ទំនងសំខាន់ផ្សេងទៀត ៖

# តើយើងខ្ញុំជានរណា

គណៈកម្មាធិការហ្វីឡាដែលហ្វៀផ្នែកទំនាក់ទំនងពលរដ្ឋ (PCHR, Philadelphia Commission on Human Relations) មានតួនាទីពង្រឹងច្បាប់សិទ្ធិពលរដ្ឋរបស់សាលាក្រុង លើកកម្ពស់សមភាព និងដោះស្រាយវិវាទដែលឧស្សាហ៍កើតឡើយបណ្ដាលពីភាពលំអៀង ។ PCHR ជួយធ្វើការសម្រុះសម្រួល និងផ្ដល់សេវាកម្មដំណោះស្រាយវិវាទផ្សេងទៀត តាមរយៈផ្នែកទំនាក់ទំនងសហគមន៍ (Community Relations Division) របស់ខ្លួន ដើម្បីឲ្យពលរដ្ឋក្បែរខាងគ្នាអាចរស់នៅប្រកបដោយសុខសន្តិភាព ប្រកបដោយការយោគយល់គ្នាច្រើន ។

PCHR មានតួនាទីការពារពលរដ្ឋ និងភៀវមិនឲ្យប្រព្រឹត្តិរើសអើងចំពោះកិច្ចការគេហកិច្ច អចលនទ្រព្យ ការងារ និងទីស្នាក់អាស្រ័យសាធារណៈ ។

គណៈកម្មាធិការយុត្តិធម៌គេហកិច្ចហ្វីឡាដែលហ្វៀ (Philadelphia Fair Housing Commission) ធ្វើកិច្ចការជាផ្នែកមួយនៃ PCHR ។ ក្រុមនេះមានតួនាទីពង្រឹង និងអប់រំអំពីច្បាប់យុត្តិធម៌គេហកិច្ចក្រុង ។ ក្រុមនេះមានតួនាទីការពារសិទ្ធិកិច្ចការសហគមន៍ជួលផ្ទះឯកជនរបស់ហ្វីឡាដែលហ្វៀ ដោយ ៖

- ដោះស្រាយបញ្ហាប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពអ្នកជួលផ្ទះ ។
- ដោះស្រាយបញ្ហាជួលផ្ទះដោយមិនយុត្តិធម៌ ។
- ជួយបង្កើតឲ្យមានទំនាក់ទំនវិជ្ជមានរវាងអ្នកជួល និងម្ចាស់ផ្ទះ ។

អង្គភាព PCHR ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1951 ។ នេះជាទីភ្នាក់ងារដែលមានវ័យចំណាស់ជាងគេមួយ ក្នុងចំណោមទីភ្នាក់ងារស្រដៀងគ្នានេះ របស់ប្រទេសយើង ។

PC
HR
PHILADELPHIA COMMISSION ON
HUMAN RELATIONS

**តើអ្នកមានសំណួរឬ? តើអ្នកមានយោបល់បន្ថែមឬ? តើអ្នកមានកង្វល់អ្វីឬ? សូមទាក់ទងយើងខ្ញុំក្នុងថ្ងៃនេះ!**

គណៈកម្មាធិការហ្វីឡាដែលហ្វៀផ្នែកទំនាក់ទំនងពលរដ្ឋ

601 Walnut Street • Suite 300 South • Philadelphia, PA 19106

ទូរស័ព្ទ ៖ 215.686.4670

F: 215.686.4684

E: pchr@phila.gov

www.phila.gov/humanrelations

ទីក្រុង
ហ្វីឡាដែលហ្វៀ

ថតរូបដោយ ៖
បុនរុឌ្ឍិសិល្បៈទិសខាងជើង (NBR, North Broad Renaissance) និងផ្នែកចងក្រងឯកសារ និងកម្មវិធីច្បាប់នៃសកលវិទ្យាល័យរដ្ឋផេនស៊ីលវេណៀ (University of Pennsylvania Documentaries & the Law Program)